ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 661 PEAC.អក

## សេចក្តីជូនដំណឹងលើកទី២

**ឈ្នួលពលកម្មតម្លើងត្រង់ស្វូរ 250KVA ចំនួន០១គ្រឿង ដើម្បីពង្រីកខ្សែបណ្តាញចែកចាយអគ្គិសនីជូនប្រជាពលរដ្ឋ នៅផ្លូវ 105K សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញនិងតំលើងត្រង់ស្វូរ 400KVA ចំនួន០១គ្រឿង ដើម្បីពង្រីកខ្សែបណ្តាញចែកចាយអគ្គិសនីជូនប្រជាពលរដ្ឋ នៅភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ**

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន /សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការឈ្នួលពលកម្មតម្លើងត្រង់ស្វូរ 250KVAចំនួន០១គ្រឿង ដើម្បីពង្រីកខ្សែបណ្តាញចែកចាយអគ្គិសនីជូនប្រជាពលរដ្ឋនៅផ្លូវ 105K សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និង តម្លើងត្រង់ស្វូរ 400 KVAចំនួន០១គ្រឿង ដើម្បីពង្រីកខ្សែបណ្តាញចែកចាយអគ្គិសនីជូនប្រជាពលរដ្ឋ នៅភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន / សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាស័យដ្ឋាន : ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពី ថ្ងៃទី ១៧-០៥-២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៥-០៥-២០១៦ វេលាម៉ោង ១១:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥ : ១៥នាទី ថ្ងៃទី ២៥-០៥-២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 17 ខែ 05 ឆ្នាំ ២០១៦

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អ៊ឹង_អ៊ីុង**

ចម្លងជូន :

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ